


# សញ្ញាបត្រវិទ្យាល័យអន្តរជាតិ

## យើងគឺជាសាលារៀនរដ្ឋវិចថូរៀជំបូងគេបង្អស់ ដែលផ្តល់ជូនសិស្ស នូវជម្រើសនៃកម្មវិធីសញ្ញាបត្រវិទ្យាល័យអន្តរជាតិ ឬ VCE ដែលជាមាគ៌ាឆ្ពោះទៅកាន់ការអប់រំឧត្តមសិក្សា។ *

អង្គការសញ្ញាបត្រវិទ្យាល័យអន្តរជាតិ (IBO) គឺជាមូលនិធិអប់រំមួយ ដែលមានបេសកកម្មដើម្បីបង្កើតពិភពលោកឱ្យកាន់តែប្រសើរឡើង តាមរយៈការអប់រំ។ ចក្ខុវិស័យជាមូលដ្ឋានរបស់ IBO គឺដើម្បីផ្តល់ជូនសិស្សនូវកម្មវិធីសិក្សាប្រកបដោយតុល្យភាព ដែលជួយជម្រុញការគិតត្រិះរិះ និងការយោគយល់វប្បធម៌គ្នាទៅវិញទៅមក។ កម្មវិធីរបស់អង្គការ មានគោលបំណងអភិវឌ្ឍជំនាញផ្នែកបញ្ញា បុគ្គល អារម្មណ៍ និងសង្គម ដែលចាំបាច់ត្រូវការដើម្បីរស់នៅ រៀនសូត្រ និងធ្វើការនៅក្នុងពិភពសាកលភាវូបនីយកម្មយ៉ាងលឿនមួយ។

### ហេតុអ្វីជ្រើសរើស IBDP?

សិក្សាដោយសិស្សច្រើនជាងមួយលាននាក់ នៅទូទាំងប្រទេសចំនួន 157 និងសាលាចំនួន 5000 នៅទូទាំងពិភពលោក កម្មវិធីសិក្សា និងការវាយតម្លៃផ្តោតជាលក្ខណៈអន្តរជាតិរបស់ IBDP ផ្តល់ជូនសិស្សនូវការត្រៀមបម្រុងដ៏ល្អសម្រាប់បញ្ហាប្រឈមនៃការអប់រំឧត្តមសិក្សា និងអាជីពនៅក្នុងពិភពដែលមានទំនាក់ទំនងគ្នា។ សាកលវិទ្យាល័យអន្តរជាតិឈានមុខគេជាច្រើន ផ្តល់ជូនជំហរជឿនលឿនសម្រាប់សិស្សបញ្ចប់ការសិក្សា IBDP ក្នុងការទទួលស្គាល់ភាពម៉ឺងម៉ាត់នៃកម្មវិធី និងសិស្សបញ្ចប់ការសិក្សា។ ការបញ្ចប់ការសិក្សា IBDP ប្រកបដោយជោគជ័យ អនុញ្ញាតឱ្យសិស្សចូលទៅរៀននៅសាកលវិទ្យាល័យកំពូលៗមួយចំនួនក្នុងប្រទេស ក៏ដូចជាសាកលវិទ្យាល័យល្អៗមួយចំនួននៅជុំវិញពិភពលោកដែរ រួមមាន Oxford, Cambridge, Harvard, Yale និង Sorbonne។

**រចនាសម្ព័ន្ធវគ្គសិក្សា៖** សិស្សត្រូវបានតម្រូវឱ្យជ្រើសរើសយកមុខវិជ្ជាមួយ ចេញពីមុខវិជ្ជានីមួយៗនៃក្រុមមុខវិជ្ជា 6។

| | |
|---|---|
| ក្រុមទី 1៖ ភាសា A | ភាសាទីមួយ (អង់គ្លេស ឬចិន) |
| ក្រុមទី 2៖ ភាសា B | ភាសាទំនើប (អង់គ្លេស បារាំង ឥណ្ឌូណេស៊ី ចិន អេស្ប៉ាញ Ab initio) |
| ក្រុមទី 3៖ បុគ្គល និងសង្គម | សេដ្ឋកិច្ច ភូមិវិទ្យា ប្រវត្តិវិទ្យា ចិត្តវិទ្យា នយោបាយសកល |
| ក្រុមទី 4៖ វិទ្យាសាស្ត្រពិសោធន៍ | ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា កីឡា លំហាត់ប្រាណ និងវិទ្យាសាស្ត្រសុខាភិបាល (SL) |
| ក្រុមទី 5៖ គណិតវិទ្យា | គណិតវិទ្យា (HL), វិធីសាស្ត្រគណិតវិទ្យា (SL), ការសិក្សាគណិតវិទ្យា (SL) |
| ក្រុមទី 6៖ សិល្បៈ | តន្ត្រី ល្ខោន សិល្បៈប្រឌិតញាណដែលអាចមើលឃើញ ឬជម្រើសផ្សេងទៀតចេញពីក្រុមមុខវិជ្ជាទី 2, 3 ឬ 4 |

បន្ថែមលើមុខវិជ្ជាចំនួនប្រាំមួយ សិស្សចូលរួមក្នុងផ្នែកសំខាន់ដោយឡែកចំនួនបីគឺ៖ ទ្រឹស្តីនៃចំណេះដឹង ជាប្រធានបទមួយដែលពិនិត្យលើចំណេះដឹង និងមូលហេតុដែលមនុស្សគិតខុសៗគ្នា។ ការតែងសេចក្តីបន្ថែម ចំនួន 4,000 ពាក្យជាអត្ថបទស្រាវជ្រាវ។ និង CAS (ការច្នៃប្រឌិត សកម្មភាព សេវាកម្ម) ដែលតម្រូវឱ្យពួកគេចូលរួម ដឹកនាំ និងរៀនសូត្រពីកម្មវិធីសកម្មភាពក្រៅកម្មវិធីសិក្សា និងបទពិសោធន៍សហគមន៍។

សម្រាប់ព័ត៌មានបន្ថែមអំពី កម្មវិធីសញ្ញាបត្រវិទ្យាល័យអន្តរជាតិ សូមមើល
**ibo.org/programmes/diploma-programme/**

** សិស្សជ្រើសរើសយក VCE ឬក៏ IBDP ដែលមាគ៌ាទាំងពីរផ្តល់ជូនសិស្សបញ្ចប់ការសិក្សាថ្នាក់ទី 12 នូវចំណាត់ថ្នាក់ចូលរៀននៅឧត្តមសិក្សាអូស្ត្រាលី (ATAR)*